# សំឡេងកែវគោះ

កាកគតិ

-សំឡេងកែវគោះ រណ្តំពីរោះ ដូចដូរ្យតន្ត្រី
ពួនក្រោមភ្លើងពណ៌ ចម្រុះរស្មី បំពក់រាត្រី
មិនឱ្យសូន្យស្ងាត់ ។

-សំឡេងកែវគោះ កាន់តែពីរោះ ពេលវាយោផាត់
ប៉ឹងបញ្ច្រាសខ្យល់ លួងសួតប្រមាត់ កុំខ្វល់វិបត្តិ
រឿងខ្វាត់ទ្រព្យធន ។

-សំឡេងកែវគោះ គោះស្ទួចកិត្តិយស កាងកូនប្រពន្ធ
គោះច្រើនកាលណា ដុល្លារជោរជន់ ហូហៀរជាទុន
មិនពន់វែកក្រ ។

-សំឡេងកែវគោះ គោះទាល់ដុះពោះ ឡានផ្ទះល្អៗ
គោះឌឺពាក្យឃ្លាន ខ្ពើមភាសាក្រ ក្បត់ពាក្យត្រដរ
កាលក្រកម្សត់ ។

-សំឡេងកែវគោះ គោះមិនដែលលស់ ចម្អកគ្រាអត់
គោះហើរកញ្ច្រៀវ ក្អាកក្អាយមិនហត់ គោះបានជាបទ
ទំនុកភ្លេងថ្មី ។

-សំឡេងកែវគោះ គោះបញ្ចៀសគ្រោះ រំដោះអវចិយ
គោះយឺតខ្លួនឡើង ប៉ើងផុតភក់ដី គោះទាញកៅអី
មន្ត្រីខ្ពស់សក្តិ ។

-សំឡេងកែវគោះ ដើម្បីល្បីឈ្មោះ រស់វៀងគ្រោះថ្នាក់
គោះគេចវេទនា គោះភ្លឺចៀសខ្វាក់ គោះទប់ឧបស័គ្គ
គោះស្ម័គ្រមុខមាត់ ។

ហាងកាហ្វេថ្ងៃទី០៨ ធ្នូ ២០០៧